ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# គម្រោងចិញ្ចឹមគោបំប៉នយកសាច់

# លក្ខណៈគ្រួសារ





# គម្រោងចិញ្ចឹមគោបំប៉នយកសាច់លក្ខណៈគ្រួសារ ចំនួន ១០ ក្បាល ដោយប្រើប្រាស់ដើមទុនផ្ទាល់ខ្លួន

**-ទីតាំងចិញ្ចឹម ÷** ភូមិជ្រោយមេត្រីលើ ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល

ស្ថានភាពចិញ្ចឹម÷ ក្នុងក្រោល

ទំហំក្រោល÷ ១៤ម៉ x ២៥ម៉ តម្លៃសាងសង់ ៨ ៤០០ ០០០៛

**-ទីកន្លែងប្រមូលទិញគោយកមកចិញ្ចឹមបំប៉ន÷** ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ

**-ស្ថានភាពគោដែលយកមកចិញ្ចឹម÷**

-ពូជ÷គោខ្មែរ ឬគោទន្លេ (ពូជគោកាត់ប្រាម៉ាន់, ហារីយ៉ាណា)

-ទម្ងន់÷ ៤២០-៤៣០ គ.ក

-អាយុ ២-៤ឆ្នាំ

-តម្លៃទិញគោចូល÷ ១២ ៥០០ រៀល - ១២ ៧០០ រៀល/គ.ក (គោរស់)

**-ចំនួនគោចិញ្ចឹមក្នុង ១ វដ្ត** ÷ ១០ ក្បាល ចំនួនវដ្ត/ឆ្នាំ÷ ៣ វដ្ត = ៣០ ក្បាល

**-គម្រោងថវិកាសម្រាប់ចិញ្ចឹមគោចំនួន ១០ក្បាល ÷**

| បរិយាយ | ថវិកា | |
|---|---|---|
| | គិតជារៀល | គិតជាដុល្លារ (១$=៤០០០ រៀល) |
| គម្រោងប៉ាន់ស្មាន | **៦២ ០០០ ០០០ រៀល** | **១៥ ៥០០ $** |
| ដើមទុនផ្ទាល់ខ្លួន (១០០%) | | |

**-រយៈពេលចិញ្ចឹម** ÷ ៩០ថ្ងៃ **ទម្ងន់កើនចំនួន.** ១.៥គ.ក/ថ្ងៃ។

| ទម្ងន់គោ មុនបំប៉ន (គ.ក) | រយៈពេលកើនទម្ងន់ (ថ្ងៃ) | ទម្ងន់កើន គ.ក/ថ្ងៃ | ទម្ងន់កើន សរុប | ទម្ងន់ទទួលបានក្រោយពីបំប៉ន (គ.ក) | | |
|---|---|---|---|---|---|---|
| | | | | ទម្ងន់សរុប | សាច់=40% | ឆ្អឹង=50%នៃចំនួនសាច់ |
| 420 | 90 | 1.5 | 135 | 555 | 222 | 100 |

**-ចំណីសម្រាប់ការចិញ្ចឹមគោបំប៉នយកសាច់÷** កាកស្រាបៀ លាយជាមួយដំឡូងចំណីសត្វម៉ាក DK, CK, CX168, ដំឡូងសំពៅលូន ពុំមានការផ្តល់ស្មៅជាចំណីទេ។ ការចិញ្ចឹមដោយស្មៅធំធាត់យឺត សាច់ស្រាល និងមានសត្វល្អិត។

**-ការប្រើចំណី÷** ជាទូទៅគឺលាយកាកស្រាបៀ២ភាគ ជាមួយដំឡូងចំណី១ភាគ។ ប្រសិនបើចង់ឱ្យគោធាប់ធំធាត់ និងមានសាច់ហាប់ធ្ងន់គឺលាយស្មើភាគរវាងកាកស្រាបៀនិងដំឡូងចំណី ប៉ុន្តែការអនុវត្តដូចនេះនឹងធ្វើឱ្យចំណាយកើនខ្ពស់។ គោ១ក្បាលប្រើចំណីចំនួន ៧គ.ក/ថ្ងៃ ដាក់២ដង/ថ្ងៃ។

**តម្លៃចំណីបច្ចុប្បន្ន÷** -កាកស្រាបៀ ១បាវទម្ងន់ ៥០គ.ក=១៥ ០០០៛

-ដំឡូង ១បាវទម្ងន់ ៣០គ.ក= ៤២ ០០០៛

**-ទីផ្សារ ÷** -កាប់ខ្លួនឯងនិងបោះដុំឱ្យអ្នកលក់រាយនៅលើទីផ្សារនៅភ្នំពេញ ខេត្តព្រៃវែង កំពង់ចាម (មិនខ្វះទីផ្សារឡើយ គឺមានតម្រូវការជាប្រចាំ)

-កាប់លក់ខ្លួនឯងចំណេញច្រើនជាងលក់គោរស់ឱ្យឈ្មួញ

**-តម្លៃ ÷** មិនប្រែប្រួលខ្លាំង

**.ក/-តម្លៃសាច់គោកាប់ខ្លួនឯងនិងបោះដុំឱ្យអ្នកលក់រាយ**

- តម្លៃក្នុងរដូវកាលធម្មតា÷ -លក់សាច់ (សាច់ទម្លាក់) បោះដុំ= ២៨ ០០០រៀល/គ.ក
  -ឆ្អឹង = ១០ ០០០ រៀល/គ.ក
- តម្លៃក្នុងរដូវកាលដែលមានតម្រូវការខ្ពស់ ឬខ្សត់គោ÷ ចន្លោះពីខែមករា ដល់ខែឧសភា
  -លក់សាច់ (សាច់ទម្លាក់) បោះដុំ= ២៩ ០០០រៀល/គ.ក
  -ឆ្អឹង = ១១ ០០០ រៀល/គ.ក

**.ខ/-តម្លៃលក់គោរស់ឱ្យឈ្មួញ÷** ១២ ៥០០ រៀល/គ.ក ទៅ ១៣ ៥០០ រៀល/គ.ក

**-លទ្ធផល÷**

| ការលក់ | ចំណូលសរុបក្នុងគោ ១ក្បាល | ចំណាយសរុបក្នុងគោ ១ក្បាល | ចំណេញសរុបក្នុងគោ ១ក្បាល |
|---|---|---|---|
| កាប់ខ្លួនឯងនិងបោះដុំ | 7,216,000 | 6,202,000 | 1,014,000 |
| លក់គោរស់ឱ្យឈ្មួញ | 6,937,500 | 6,202,000 | 735,500 |

-ចំណាយ និងចំណូលលម្អិតពីការចិញ្ចឹមគោ ១ក្បាល សម្រាប់ការកាប់ខ្លួនឯងនិងបោះដុំឱ្យទីផ្សារ

| បរិយាយ | ទម្ងន់/១ក្បាល (គ.ក) | ចំនួនគោចិញ្ចឹម (ក្បាល) | ទម្ងន់សរុប (គ.ក) | តម្លៃរៀល/គ.ក | ចំនួនសាររំលស់ | ទឹកប្រាក់សរុបគោ១ក្បាល | ទឹកប្រាក់សរុប ១វដ្ត (រៀល) គោ ៧ក្បាល |
|---|---|---|---|---|---|---|---|
| **១-ចំណូលសរុប** | | | | | | **7,216,000** | **72,160,000** |
| ចំណូលពីការលក់សាច់ | 222 | 10 | 2,220 | 28,000 | | 6,216,000 | 62,160,000 |
| ចំណូលពីការលក់ឆ្អឹង | 100 | 10 | 1,000 | 10,000 | | 1,000,000 | 10,000,000 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួលសរុប + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **6,202,000** | **62,020,000** |
| **២.ក.ចំណាយប្រែប្រួលសរុប** | | | | | | **5,957,000** | **59,570,000** |
| ទិញគោ | 420 | 10 | 4,200 | 12,700 | | 5,334,000 | 53,340,000 |
| កាកស្រាបៀ (៤គ.ក/ថ្ងៃ x ៩០ថ្ងៃ) | 360 | 10 | 3,600 | 300 | | 108,000 | 1,080,000 |
| ដំឡូង (៣គ.ក/ថ្ងៃ x ៩០ថ្ងៃ) | 270 | 10 | 2,700 | 1,400 | | 378,000 | 3,780,000 |
| ថ្នាំបំប៉ន+ ថ្នាំទម្លាក់សត្វល្អិត | | 10 | | | | 20,000 | 200,000 |
| ថ្លៃឈ្នួលវះ (៤០០០០៛/ក្បាល) | | 10 | | | | 40,000 | 400,000 |
| បង់ថ្លៃទីសត្តឃាត (៧០០០៛/ក្បាល) | | 10 | | | | 7,000 | 70,000 |
| ថ្លៃភ្លើងបូមទឹកស្រោចគោ | | 10 | | | | 30,000 | 300,000 |
| ថ្លៃដឹកមកកន្លែងចិញ្ចឹម | | 10 | | | | 40,000 | 400,000 |
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរសរុប** | | | | | | **245,000** | **2,450,000** |
| ជួលដី (តម្លៃក្នុងរយៈពេល១ឆ្នាំ) | 1,050,000 | | | | 3 | 35,000 | 350,000 |
| ធ្វើក្រោល (14m x 425m x 6$/m2) រយៈពេលប្រើ១៨ខែ ចិញ្ចឹមបាន៤វដ្ត | 8,400,000 | | | | 4 | 210,000 | 2,100,000 |
| **៣-ចំណេញដុលសរុប** | | | | | | **1,014,000** | **10,140,000** |
| ថ្លៃដើម/ក្បាល | | | | | | | 6,202,000 |
| ចំណេញ/ក្បាល | | | | | | | 1,014,000 |

## -ចំណាយ និងចំណូលលម្អិតពីការចិញ្ចឹមគោ ១ក្បាល សម្រាប់ការលក់គោរស់ឱ្យឈ្មួញ

| បរិយាយ | ទម្ងន់/ ១ក្បាល (គ.ក) | ចំនួនគោ ចិញ្ចឹម (ក្បាល) | ទម្ងន់ សរុប (គ.ក) | តម្លៃ រៀល/ គ.ក | ចំនួន សារ រំលស់ | ទឹកប្រាក់ សរុប គោ១ក្បាល | ទឹកប្រាក់សរុប ១វដ្ត (រៀល) គោ ៧ក្បាល |
|---|---|---|---|---|---|---|---|
| **១-ចំណូលសរុប** | | | | | | **6,937,500** | **69,375,000** |
| ចំណូលពីការលក់គោរស់ | 555 | 10 | 5,550 | 12,500 | | 6,937,500 | 69,375,000 |
| ចំណូលពីការលក់ឆ្អឹង | 0 | 0 | 0 | 0 | | 0 | 0 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួលសរុប + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **6,202,000** | **62,020,000** |
| **២.ក.ចំណាយប្រែប្រួលសរុប** | | | | | | **5,957,000** | **59,570,000** |
| ទិញគោ | 420 | 10 | 4,200 | 12,700 | | 5,334,000 | 53,340,000 |
| កាកស្រាបៀ (៤គ.ក/ថ្ងៃ x ៩០ថ្ងៃ) | 360 | 10 | 3,600 | 300 | | 108,000 | 1,080,000 |
| ដំឡូង (៣គ.ក/ថ្ងៃ x ៩០ថ្ងៃ) | 270 | 10 | 2,700 | 1,400 | | 378,000 | 3,780,000 |
| ថ្នាំបំប៉ន+ ថ្នាំទម្លាក់សត្វល្អិត | | 10 | | | | 20,000 | 200,000 |
| ថ្លៃឈ្នួលវះ (៤០០០០៛/ក្បាល) | | 10 | | | | 40,000 | 400,000 |
| បង់ថ្លៃទីសត្តឃាត (៧០០០៛/ក្បាល) | | 10 | | | | 7,000 | 70,000 |
| ថ្លៃភ្លើងបូមទឹកស្រោចគោ | | 10 | | | | 30,000 | 300,000 |
| ថ្លៃដឹកមកកន្លែងចិញ្ចឹម | | 10 | | | | 40,000 | 400,000 |
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរសរុប** | | | | | | **245,000** | **2,450,000** |
| ជួលដី (តម្លៃក្នុងរយៈពេល១ឆ្នាំ) | 1,050,000 | | | | 3 | 35,000 | 350,000 |
| ធ្វើក្រោល (14m x 425m x 6$/m2) រយៈពេលប្រើ១៨ខែ ចិញ្ចឹមបាន៤វដ្ត | 8,400,000 | | | | 4 | 210,000 | 2,100,000 |
| **៣-ចំណេញដុលសរុប** | | | | | | **735,500** | **7,355,000** |
| ថ្លៃដើម/ក្បាល | | | | | | | 6,202,000 |
| ចំណេញ/ក្បាល | | | | | | | 735,500 |

**-ចំណុចខ្លាំង÷**

-អ្នកចិញ្ចឹមមានការយល់ដឹងខ្ពស់ មានបទពិសោធន៍ល្អក្នុងការចិញ្ចឹម

-ទីផ្សារមានវិសាលភាពធំ សាច់គោប្រភេទនេះមានតម្រូវការខ្ពស់ ងាយលក់ និងមានតម្លៃល្អ

-ងាយចិញ្ចឹម អត្រាស្លាប់តិចគឺ១% ទទួលបានប្រាក់ចំណេញសមរម្យ

-មិនពិបាកក្នុងការដើររកចំណី ចំណីងាយរកទិញ ដូចជាកាកស្រាបៀនិងចំណីផ្សំពីដំឡូងមីផលិតក្នុងស្រុកដែលឈ្មួញដឹកយកមកលក់ដល់ទីកន្លែងចិញ្ចឹម។

**-បញ្ហាប្រឈម÷**

-ពុំមានទីកន្លែងចិញ្ចឹមផ្ទាល់ខ្លួន ភាគច្រើនជួលដីគេ ដែលអាចប៉ះពាល់ដល់និរន្តភាពនៃមុខរបរ

-ពុំមានការចិញ្ចឹមគោពូជ គឺពឹងផ្អែកលើការដើរប្រមូលទិញគោស្គមៗពីប្រជាពលរដ្ឋដែលស៊ីមិនគ្រប់គ្រាន់ឬខ្វះការថែទាំយកមកចិញ្ចឹមបំប៉ន ដែលការប្រមូលទិញគោមានការលំបាក មានឈ្មួញដើរប្រមូលទិញច្រើនប្រកួតប្រជែងគ្នា ពេលខ្លះត្រូវទៅទិញនៅខេត្តឆ្ងាយៗជិតព្រំដែនប្រទេសថៃ

-រដូវភ្លៀងសត្វគោច្រើនមានជំងឺអុតក្តាម ដែលទាមទារឱ្យមានការថែទាំហ្មត់ចត់

**-សេចក្តីសន្និដ្ឋាន÷** តាមការបញ្ជាក់របស់អ្នកចិញ្ចឹម ការចិញ្ចឹមគោបំប៉នយកសាច់នេះមិនដែលជួបបញ្ហាខាតបង់អ្វីធ្ងន់ធ្ងរឡើយ ដោយសារអ្នកចិញ្ចឹមអាចគ្រប់គ្រងបានទាំងចំណី និងជំងឺ។ ម៉្យាងទៀត ផ្អែកតាមនិន្នាការតម្លៃក្នុងរយៈពេល២-៣ឆ្នាំចុងក្រោយនេះតម្លៃបោះដុំសាច់គោគឺមិនក្រោម ២៧ ០០០៛/គ.ក និងតម្លៃឆ្អឹងគឺមិនក្រោម ៩០០០៛/គ.ក ឡើយ។ តម្លៃដែលអាចទទួលបានប្រាក់ចំណេញគឺសាច់តម្លៃពី ២៦ ០០០៛/គ.ក ឡើងទៅ និងឆ្អឹងតម្លៃពី ៨០០០៛/គ.កឡើងទៅ។ រីឯទីផ្សារក៏ទូលំទូលាយដែរ។